01330320

**Declassified to Public**
**12 June 2020**

D193/65

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 27-Sep-2016, 09:21
CMS/CFO: Ly Bunloung

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាកែប្រែដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បញ្ចូលឯកសារនៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធមន្ទីរ ស-២១ ទៅក្នុងសំណុំរឿង០០២

---

**<u>ផ្ញើជូន៖</u>** **អង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

## I- ប្រវត្តិនីតិវិធី

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និង ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៤។

2. នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ អតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon បានចេញ*ដីកាសម្រេចសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០២* ("ដីកាសម្រេចចុះថ្ងៃទី ១៤ ខែ តុលា")[1]។ ខ្ញុំសូមរម្លឹក និងដាក់បញ្ចូលជាឯកសារយោងនូវប្រវត្តិនីតិវិធីដែលត្រូវបានសង្ខេបក្នុងកថាខណ្ឌ ១ ដល់ ៧ ក្នុងដីកាសម្រេចចុះថ្ងៃទី ១៤ ខែ តុលានេះ ដែលបានដាក់កំហិត និងទម្រង់បែបបទមួយចំនួនស្តីពីការដាក់បង្ហាញចម្លើយទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង ០០២/០២[2]។

3. នៅថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១៦ ស.ព.អ បានដាក់*សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ដែលពាក់ព័ន្ធនឹង ស-២១ ទៅក្នុងសំណុំរឿង ០០២* ("សំណើ")[3]។ នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានចេញ*ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនានានៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធទៅនឹង ស-២១ ទៅក្នុងសំណុំរឿង ០០២* ("*ដីកាសម្រេច*") ដោយបានអនុញ្ញាតឲ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយចំនួនបី និងកំណត់ហេតុនៃកិច្ចស៊ើបសួរចំនួនមួយទាក់ទង កាំង ហ្គេកអ៊ាវ ហៅ ឌុច[4]។

4. លក្ខខណ្ឌនៃការប្រើប្រាស់ភស្តុតាងដែលត្រូវបានដាក់បង្ហាញនេះ បានដាក់ការកំហិតមួយចំនួន រួមទាំងការតម្រូវឲ្យប្រើប្រាស់រហស្សនាមសម្រាប់ កាំង ហ្គេកអ៊ាវ ហៅ ឌុច និងតាមរយៈការកោស

---

[1] សំណុំរឿង ០០៤-D193/4, *ដីកាសម្រេចសំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំ ជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០២*, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤, កថាខណ្ឌ ១៩-២០។ សំណុំរឿង ០០៤-D193/2, *សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១នៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០២*, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤។ សំណុំរឿង ០០៤-D193/3, *សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទីមួយនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០២*, ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៤។

[2] ដីកាសម្រេចចុះថ្ងៃទី ១៤ ខែ តុលា, កថាខណ្ឌ ១៩-២០, ២៣។

[3] សំណុំរឿង ០០៤-D193/63, *សំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៤ដែលពាក់ព័ន្ធនឹង ស-២១ ទៅក្នុងសំណុំរឿង ០០២*, ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១៦។

[4] សំណុំរឿង ០០៤-D193/64, *ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារនានានៃសំណុំរឿង០០៤ ដែលពាក់ព័ន្ធទៅនឹង ស-២១ ទៅក្នុងសំណុំរឿង ០០២, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៦*។

លុបផ្នែកនានានៃកំណត់ហេតុនៃកិច្ចស៊ើបសួរ។ ប៉ុន្តែដោយហេតុថាសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច គឺជាទណ្ឌិតមុននៃតុលាការនេះ និងជាឥស្សរជនដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅកម្ពុជា ការប្រើប្រាស់វិធានការទាំងនេះជាមួយគាត់គឺជាការពុំចាំបាច់ និងផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ។ អាស្រ័យហេតុនេះ ខ្ញុំសូមកែប្រែលក្ខខណ្ឌនៃការប្រើប្រាស់ភស្តុតាងដែលត្រូវបានដាក់បង្ហាញនេះ ត្រង់ចំណុចទាក់ទង កាំង ហ្កេកអ៊ាវ ហៅ ឌុច ដូចខាងក្រោម។

5. ដីកានេះត្រូវបានដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសម្អាងហេតុខាងលើ យើង៖**

6. **អនុញ្ញាត** ឲ្យដាក់បង្ហាញឯកសារចំនួនប្រាំដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ក នៃសំណើនេះ ទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីក្នុងសំណុំរឿង ០០២/០២ ដោយមានការកោសលុបតែចំពោះកំណត់ហេតុនៃកិច្ចស៊ើបសួរ D119/127 ទាក់ទង ញ៉ែម អេន តែប៉ុណ្ណោះ។ ដោយសារភាពសម្ងាត់ និងភាពរសើបនៃកិច្ចស៊ើបសួរដែលកំពុងប្រព្រឹត្តទៅក្នុងសំណុំរឿង ០០៤ ការដាក់បង្ហាញនេះត្រូវបានអនុញ្ញាតដោយមានទម្រង់បែបបទ និងការកំហិតដូចខាងក្រោម៖

(ក) ក្នុងករណីដែលសាក្សីនានាដែលកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម ពួកគាត់អាចធ្វើដូច្នោះក្នុងសវនាការជាចំហរ ហើយវិធានការការពារដទៃទៀតពុំមានភាពចាំបាច់ឡើយ។

(ខ) គ្មានសម្ភារៈណាមួយដែលត្រូវបានផ្តល់អនុលោមតាមដីកាសម្រេចនេះ ត្រូវបានផ្សព្វផ្សាយឲ្យហួសពីអ្វីដែលត្រូវបានបង្ហាញជាក់លាក់នៅក្នុងដីកាសម្រេចនេះឡើយ។

(គ) គ្មានសម្ភារៈណាមួយដែលត្រូវបានផ្តល់អនុលោមតាមដីកាសម្រេចនេះ ត្រូវបានផ្សព្វផ្សាយទៅសាធារណជនក្នុងទម្រង់ណាមួយ ឬតាមរយៈទម្រង់ណាមួយនៃប្រព័ន្ធផ្សព្វផ្សាយ ហួសពីភស្តុតាងដែលបានបង្ហាញក្នុងសវនាការជាចំហរឡើយ។

(ឃ) ភាគី មេធាវីការពារក្តីណា ឬបុគ្គលដទៃទៀតដែលអានពី លើកឡើង ឬប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយ ដែលត្រូវបានដាក់បង្ហាញ ត្រូវហៅសាក្សីតាមរយៈរហស្សនាមរបស់គាត់ដែលត្រូវបានដាក់ឲ្យ សម្រាប់សំណុំរឿង ០០២/០១ និងប្រើប្រាស់ការពិពណ៌នានានាដែលត្រូវបានពិចារណាដោយសមហេតុផលដើម្បីបញ្ចៀសការកំណត់អត្តសញ្ញាណសាក្សីតាមរយៈព័ត៌មានដទៃទៀត។

(ង) ឯកសារនេះត្រូវផ្តល់ទៅមេធាវីការពារក្តីរបស់ជនជាប់ចោទ, មេធាវីការពារក្តីប្រចាំការរបស់ ខៀវ សំផន (“មេធាវីការពារក្តីប្រចាំការ”) និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅអេឡិចត្រូនិក។

(ច) មេធាវីការពារក្តី, មេធាវីការពារក្តីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់បង្ហាញឯកសារដែលបានផ្តល់ឲ្យ អនុលោមតាមដីកាសម្រេចនេះ ទៅសមាជិកទាំងឡាយនៃក្រុមរបស់ផងខ្លួនដែលត្រូវបានជួលជាផ្លូវការក្រោមវិធាន២២(៥)នៃវិធានផ្ទៃក្នុង និងវិធាន១២*ស្ទួនពីរ*(៤) ព្រមជាមួយបុគ្គលិកហាត់ការរបស់ខ្លួនដែលត្រូវបានតែងតាំងជាផ្លូវការប៉ុណ្ណោះ។

(ឆ) មេធាវីការពារក្តី មេធាវីការពារក្តីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពុំត្រូវបានអនុញ្ញាតឲ្យព្រីន ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងសំណៅនានានៃឯកសារដើមដែលត្រូវបានផ្តល់ទៅពួកគាត់ ឲ្យហួសពីការប្រើប្រាស់ផ្ទៃក្នុងនូវសម្ភារៈ នោះពីសំណាក់សមាជិកទាំងឡាយនៃក្រុមនីមួយៗរបស់ពួកគាត់ ដែលត្រូវបានណែនាំ ឬអនុញ្ញាតឲ្យចូលពិនិត្យសម្ភារៈសម្ងាត់ឡើយ។

(ជ) មេធាវីការពារក្តី មេធាវីការពារក្តីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវថែរក្សាកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយ ក្នុងលក្ខណៈដែលអាចពិនិត្យមើលបាន នូវសំណៅនានាដែលពួកគាត់ព្រីន ផលិតឡើងវិញ ថតចម្លង ស្កេន ឬចម្លងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និង

(ឈ) ប្រសិនបើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២/០២ ដឹងអំពីការចម្លងដោយគ្មានការអនុញ្ញាតនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីសម្រាប់ ការដាក់បង្ហាញ ខ្លួនត្រូវចាត់វិធានការទាំងអស់ជាបន្ទាន់ដើម្បីទទួលបាន និងប្រគល់សងវិញនូវសំណៅនោះ ជូន ស.ច.ស និង

(ញ) ប្រសិនបើសមាជិកណាម្នាក់នៃភាគី ឬអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភលក្ខខណ្ឌ និងការកំហិតទាំងនេះ ខ្លួនត្រូវរាយការណ៍អំពីការរំលោភនេះជូន ស.ច.ស។

7. **បញ្ជាក់បំភ្លឺ** ថាសម្រាប់គោលបំណងនៃដីកាសម្រេចនេះ “សាធារណៈ” មានន័យ និងរួមបញ្ចូលបុគ្គលទាំងអស់ រដ្ឋាភិបាល អង្គការ អង្គភាព កូនក្តី សមាគម និងក្រុមទាំងអស់ ក្រៅពីចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល មន្ត្រីបុគ្គលិកនៃផ្នែកគ្រប់គ្រងតុលាការ សហព្រះរាជអាជ្ញា និង

តំណាងរបស់គាត់ ជនជាប់ចោទ និយោជិកនានាដែលត្រូវបានជួលជាផ្លូវការក្រោមវិធាន២២(៥) និងវិធាន១២*ស្ទួនពីរ*(៤) នៃវិធានផ្ទៃក្នុង ដែលត្រូវបានអនុញ្ញាតដោយមេធាវីការពារក្តី មេធាវីការពារក្តីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់នេះ។ “សាធារណជន” ក៏រួមបញ្ចូលដោយគ្មានកំណត់ នូវសមាជិកគ្រួសារជនជាប់ចោទ មិត្តភ័ក្តិ និង ដៃគូ ជនសង្ស័យ មេធាវីការពារក្តី និងសមាជិកនៃមន្ត្រីបុគ្គលិករបស់ពួកគាត់ក្នុងសំណុំរឿង ឬកិច្ចដំណើរការនីតិវិធីដទៃទៀតនៅចំពោះមុខ អ.វ.ត.ក, ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន។

8. **បន្ទាប់** ថាលក្ខខណ្ឌ និងការកំហិតខាងលើ ស្ថិតនៅជាធរមាន រហូតដល់មានការកែប្រែដោយដីកាសម្រេចជាក់លាក់មួយពីសំណាក់ ស.ច.ស ឬនៅពេលដែលកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤ ត្រូវបានចាត់ទុកថាត្រូវបានបិទបញ្ចប់។

ភ្នំពេញ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦

ហត្ថលេខា និងត្រា

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d’instruction International**